# វេទិកាផ្គូផ្គងធុរកិច្ចបច្ចេកវិទ្យា
# កសិកម្មទំនើប និងថាមពលថ្មី កម្ពុជា-ចិនឆ្នាំ២០១៥
# ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ

នាថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៥ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ដោយមានការឯកភាពដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី** ប្រគល់សិទ្ធិជូន **ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី** អនុរដ្ឋលេខាធិការ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានដឹកនាំ និងជាគណៈអធិបតីក្នុងវេទិកាផ្គូផ្គងធុរកិច្ចបច្ចេកវិទ្យាកសិកម្មទំនើប និងថាមពលថ្មីកម្ពុជា-ចិនឆ្នាំ២០១៥។

វេទិកានេះបានសហការរៀបចំដោយនាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា អគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមួយមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាចិន-អាស៊ាន ខេត្តក្វាន់ស៊ី ដោយមានការចូលរួមពីអ្នកគ្រប់គ្រងឬម្ចាស់ ក្រុមហ៊ុន សហគ្រាស រោងចក្រ សិប្បកម្ម សកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវ និងមន្ត្រីរាជការនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម សរុបទាំងអស់ចំនួនប្រមាណ ១០០នាក់។ គោលបំណងនៃវេទិកាគឺ ផ្តល់ឱកាសដល់អ្នកគ្រប់ឬម្ចាស់ក្រុមហ៊ុន សហគ្រាស រោងចក្រ សិប្បកម្ម នៃប្រទេសកម្ពុជានិងប្រទេសចិនជួបគ្នាដើម្បីពិភាក្សា ផ្លាស់ប្តូរចំណេះដឹង ពិសោធន៍ និងបង្កើតសហប្រតិបត្តិការផ្ទេរបច្ចេកវិទ្យារវាងវិស័យឯកជននៃប្រទេសទាំងពីរ។

តំណាងក្រុមហ៊ុននៃប្រទេសចិន បានធ្វើបទបង្ហាញពីគម្រោងដែលនឹងត្រូវសហការជាមួយក្រុមហ៊ុននៃប្រទេសកម្ពុជាលើខ្លឹមសារសំខាន់ៗមួយចំនួនរួមមាន៖

- ការប្រើប្រាស់ថាមពលព្រះអាទិត្យ គឺជាបច្ចេកវិទ្យាមួយដែលកំពុងអនុវត្តដោយវិទ្យាស្ថានអនុវត្តន៍រូបវិទ្យានៃបណ្ឌិតសភាវិទ្យាសាស្ត្រខេត្តក្វាន់ស៊ី គម្រោងមានដូចជា ភ្លើងបំភ្លឺសាធារណៈ ភ្លើងបំភ្លឺឆ្លាតវៃ និងភ្លើងបំភ្លឺដោយប្រើបច្ចេកវិទ្យាចុងក្រោយ LED
- គម្រោងរបស់វិទ្យាស្ថានឧស្សាហកម្មគីមី ខេត្តក្វាងស៊ី អំពីបច្ចេកវិទ្យាថ្មី និងផលិតផលថ្មី ដូចជា ថ្នាំសម្លាប់សត្វល្អិត ថ្នាំលាប ជាដើម
- គម្រោងរបស់ក្រុមហ៊ុនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាជាក អំពីបច្ចេកវិទ្យាសម្ងួត ដូចជាសម្ងួត ស្លឹកតែ ផ្កាម្លិះ សូត្រ ស្លឹកថ្នាំ ។ល។
- គម្រោងរបស់ក្រុមហ៊ុនបច្ចេកវិទ្យា KESUO NANNING ខូអិលធីឌី លើថាមពលកំដៅឬសម្ងួតដើរដោយពន្លឺព្រះអាទិត្យ ដូចជាសម្ងួតគ្រាប់ធញ្ញជាតិជាដើម
- គម្រោងរបស់ក្រុមហ៊ុន ជៀយាំក្វាងស៊ិក ម៉ាជៀចាវ ផ្គត់ផ្គង់ឧបករណ៍ សម្ភារៈប្រើពន្លឺព្រះអាទិត្យ
- គម្រោងរបស់ក្រុមហ៊ុនវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា កូប៉ូក្វាងស៊ី ផ្តល់ប្រឹក្សាយោបល់ និងបណ្តុះបណ្តាលលើការងារផ្ទេរបច្ចេកវិទ្យា

ព្រឹត្តិការនេះពិតជាមានសារៈសំខាន់ណាស់ដោយបានបង្កលក្ខណៈឱ្យក្រុមហ៊ុនឯកជននៃប្រទេសទាំងពីរមានឱកាសបានជួបគ្នា និងពិភាក្សាផ្លាស់ប្តូរពិសោធន៍ នឹងបង្កើតសហប្រតិបត្តិការរវាងគ្នានាពេលខាងមុខ ដែលជាលទ្ធផលក្រុមហ៊ុននៃប្រទេសចិនត្រូវបានទទួលការចាប់អារម្មណ៍ពីក្រុមហ៊ុននៃប្រទេសកម្ពុជាតាមរយៈការចុះហត្ថលេខាលើកិច្ចព្រមព្រៀងផ្តួចផ្តើមសហប្រតិបត្តិការគម្រោងចំនួន២៨។

ជាកិច្ចបញ្ចប់ **ឯកឧត្តមបណ្ឌិត ទឹង ស៊ីនី** បានផ្តល់អនុសាសន៍ឱ្យក្រុមហ៊ុនដែលបានចុះកិច្ចព្រមព្រៀងបន្តសហការគ្នាដើម្បីឈានទៅអនុវត្តគម្រោងនាពេលខាងមុខ និងទទួលបានបច្ចេកវិទ្យាថ្មីៗពីប្រទេសចិន ដើម្បីអភិវឌ្ឍប្រទេសកម្ពុជាឱ្យមានការរីកចម្រើន និងដើរទាន់ប្រទេសសមាជិកអាស៊ាន ជាពិសេសការឈានចូលសមាហរណកម្មសេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥នេះ។

## រូបភាពសកម្មភាពនៃវេទិកាផ្គូផ្គងធុរកិច្ចបច្ចេកវិទ្យាកសិកម្មទំនើប និងថាមពលថ្មីកម្ពុជា-ចិនឆ្នាំ២០១៥

(**រូបភាពបើកកម្មវិធី**)






(រូបភាពកិច្ចពិភាក្សារវាងក្រុមហ៊ុនចិន និងកម្ពុជា)



(រូបភាពចុះហត្ថលេខាលើកិច្ចព្រមព្រៀង)




